1436 (០៩ ទំព័រ)

# សេចក្តីរាយការណ៍

គិតពីថ្ងៃទី ៥ខែ៥ឆ្នាំ១៩៧៧ ដល់ថ្ងៃទី ២៩ ខែ៥ ឆ្នាំ១៩៧៧ មានដូចខាងក្រោមនេះ

## I ស្ថានភាពការណ៍ខ្មាំង :

១- ខ្មាំងពីខាងក្រៅ វាបានរំលោភលើព្រំដែនយើង ពីថ្ងៃទី១២ ខែ៥ ឆ្នាំ១៩៧៧វេលាម៉ោង ៧ព្រឹក មានយន្តហោះ កាំភ្លើងធំ និងរថក្រោះចំនួន ៧គ្រឿង ។ យើងបានប្រយុទ្ធយ៉ាងស្វិតស្វាញតទល់នឹងរថក្រោះនៅក្នុងព្រំដែន តែខ្មាំងវាបុកពីចំហៀង កិនព្រំដែនយុទ្ធជនយើង ពលីកម្មអស់៣នាក់ បាត់ខ្លួនអស់ ២នាក់ និងកាំភ្លើង អាកា ២ដើមផង ។ ក្រៅពីនេះមានរបួសចំនួន១៣នាក់ ។

កាលពីថ្ងៃទី១៩-៥-៧៧. មានវៀតចំនួន១០នាក់ បានចូលរំលោភមកក្នុងដីយើងជំរៅ១០ម៉ នៅឡាក់ ៤២ ពួកវាជាន់ត្រូវមីនយើង១គ្រាប់ ព្រមទាំងយើងបាញ់ទៅលើវាផង ពួកវាមានរបួសមួយចំនួន ដោយ វាអូសគ្នាវាចូលទៅក្នុងដីវាវិញអស់ ។

កាលពីថ្ងៃទី៧ ខែ៥-៧៧ មានពួកខ្មែរសេរីចំនួន២៥នាក់ មានកាំភ្លើងគ្រប់ដៃ ចូលមកវាយប្លន់យក ប្រជាជនយើង នៅចំការកប្បាសតាគ្រក ក្នុងឃុំជីលាង ស្រុកបាត់តំបង អស់ចំនួន៥០នាក់ទាំងក្មេងទាំងចាស់ ពួកវាបានដុតរោងដាក់ស្រូវយើងមួយ ខូចខាតអស់ស្រូវ ៥០បាវ និងបាញ់ស្លាប់កម្មាភិបាលយើងម្នាក់ ។ តែពួក វានេះត្រូវកងទ័ពយើងតាមវាយកំទេចវាមិនឱ្យចេញក្រៅបាន ពួកនេះត្រូវយើងវាយបែកខ្ចាត់ខ្ចាយ និងស្លាប់មួយចំនួន ។ នៅសល់មួយចំនួនកំពុងព័ទ្ធនឹងតាមដានកំទេចវាតទៅទៀត ។

២- ខាងក្នុងស្រុកវិញ ខ្មាំងវាបាន ធ្វើសកម្មភាពទប់ទល់ប្រឆាំងនឹងបដិវត្តន៍យើងជាបន្តបន្ទាប់ដែរ ។ ពីថ្ងៃទី៧-៥-៧៧ វាបានលបដុតបស្សិវិទ្យុបាត់តំបងខូចខាតអស់មួយចំនួន ។ នៅថ្ងៃទី៧នេះដែរ ខ្មាំងចំនួន ២នាក់ វាជិះឡានស្ទីងលដ័ក្ខរ ត្រង់ម្តុំបាណន់ នៅពេលម៉ោង៨យប់ ជួបយុទ្ធជនយើងសួរវាថា អ្នកណាជិះ វា ក៏បាញ់ប្រាវ ត្រូវរបួសយុទ្ធជនយើង ១ នាក់ លុះដល់យុទ្ធជនយើងបាញ់តបវិញ វាក៏រត់គេចសំដៅទៅព្រៃបាត់ទៅ។ យប់ដដែលនេះដែរ ខ្មាំងបានលបចូល មន្ទីរចាត់ការស្រុកសង្កែ ត្រង់ម្តុំបាយដំរាំ យុទ្ធជនយើងសួរថា វារត់ យើងក៏បាញ់ តែវារត់បាត់ទៅ ។ លុះព្រឹកឡើងបានឃើញមនុស្សម្នាក់ ត្រូវរបួសដោយយើងបាញ់ពីយប់មិញ យើងបានចាប់មកឃុំឃាំងនិងសាកសួរតាមដានហើយ ។ នៅក្នុងយប់ដដែលនេះដែរខ្មាំងបានលបចូលក្នុងផ្ទះបាយ ក្នុងមន្ទីរតំបន់ទី១ នៅភូមិឃើទាល យុទ្ធជនយើងឃើញវាទាន់ក៏បាញ់ តែមិនត្រូវវាទេ វារត់រួចបាត់ទាំង ២ នាក់ ។

នៅតំបន់ទី៥ មានខ្មាំងចំនួន ៩ នាក់ រត់ចូលព្រៃ ប្រុស៦ នាក់ ស្រី ៣ នាក់ បានរត់ចូលព្រៃ នៅម្តុំព្រៃដូនខៀវខាងត្បូងកំរៀង ពួកនេះដែលរត់ចេញពីកងចល័ត យើងកំពុងដេញតាមរាល់ថ្ងៃ បាន ជួបវាម្តង បាញ់ត្រូវជុះការីម៉ល់ អង្ករ គ្រឿងទៀត និងឡឹក នៅកន្លែងវាលំរាក តែមិនត្រូវវា យើងកំពុងដេញ តាមវាតទៅទៀត ។ ក្រៅពីនេះ មានពលនារត់ទៅថៃខ្លះដែរ តែបើប្រៀបធៀបពីខែមុន ឃើញ ថាមានចំនួនតិចជាងមុនច្រើនណាស់ ហើយអ្នកដែលរត់ច្រើនយើងកំទេចបានផង ។ ខាងផ្នែកសីលធម៌បុរស នារីមានមួយចំនួនដែរ នៅតាមសហករណ៍ ភាគច្រើនសមាសភាព១៧ មេសា ផ្នែកមូលដ្ឋានក៏មានខ្លះដែរ តែមានចំនួនតិចតួចទេ ។ ព្រមជាមួយនេះ ខ្មាំងមានធ្វើសកម្មភាពលួចលាក់ស្រូវអង្ករ កន្លែងខ្លះ ១ តៅ កន្លែងខ្លះកន្លះបាវ និងអំបិល ប្រហុក បាយក្រៀម តែយើងចេះតែរកឃើញរាល់ថ្ងៃ ។ នៅតំបន់ទី៥ មានអាខ្មាំងម្នាក់វាជិះឧបាយកលធ្វើជាខ្មោចលងពេលយប់ ដោយចោលដុំដី ដោយជាល់ទឹក ដោយចោលស្បែក ជើង លើគេលើអងដើរទៅភ្នំស្រែ នៅស្រុកប្រនេតព្រះ តែអានេះត្រូវយើងចាប់ហើយ ។

នៅតំបន់ទី៤ ដដែល មានប្រជាជនយើងម្នាក់ បានបះបោរទៅខាងឧត្តរមានជ័យ ដើម្បីរកដីកកំ រទេះនៅក្នុងព្រៃ តែឈ្មោះនេះត្រូវបាត់ខ្លួន ដោយពួកចោរព្រៃវាចាប់ ។ ក្នុងខែ៥នេះមានកុមារ ម្នាក់ សមាសភាព ១៧ មេសា បានដេញចាក់កុមារម្នាក់ទៀត តែត្រូវយើងចាប់បានហើយ ។

នៅតំបន់ទី ៣ តាមការពិនិត្យរួមក្នុងតំបន់ទាំងមូល ចាប់ពីថ្ងៃទី ១៥-៥-៧៧ មកឃើញថា មានសភាពខ្មាំងប្រែប្រួលខ្លះ ទូទាំងតំបន់ ពិសេសសភាពការណ៍ខ្មាំងដែលមានបាតុភាពខ្លាំងជាងគេគឺក្នុង

ស្រុកភ្នំសំពៅ ។ កាលពីថ្ងៃទី ២១-៥-៧៧ វេលាម៉ោង៤រសៀល នៅមុំបួនផ្លូវ ដីក្រហម មានក្មេងឃ្វាលគោក្របី បានប្រទាល់ឃើញខ្មាំងម្នាក់ស្លៀកខោក្រហម ពាក់អាវធម្មតា មានកាំភ្លើងអាកា ១ ដើម វាបានលួចកាត់ផ្លូវទៅតាវ៉ែន តាក្រោម និងផ្លូវជាតិ ក្រោយពីមានសភាពការណ៍ដូច្នេះហើយ យើងមានវិធានការស្ទាក់ចាប់វាជាមួយនឹងកងទ័ព តែមិនឃើញ មិនដឹងជាវាទៅខាងណា ។ និយាយរួមក្នុងតំបន់ទី៣ ចាប់ពីថ្ងៃទី ១៥-៥-៧៧ រហូតដល់ថ្ងៃទី២៦-៥-៧៧ នេះ យើងបានបោសសំអាតនិងចាប់វាបាន ៤២ ក្បាល ។ នៅយប់ថ្ងៃទី ២៦-៥-៧៧ នៅសហករណ៍អូរព្រហ្មសាទ ក្នុងភូមិស្រះរាំង យើងចាប់វាលួចចំរៀវបានកាំភ្លើងអិមសី ៣ ដើម និងគ្រាប់ ១៥០០ គ្រាប់បែកដៃ ១០ គ្រាប់ និងបង់ដាក់គ្រាប់ ១២ បង់ យើងចាប់បាន ៧ ក្បាល មានឈ្មោះអាកុយជាមេគេ ហើយរត់រួច២ នាក់ អាដែលរត់រួចនោះ គឺឈ្មោះវាអាតាំម្នាក់ទៀតយើងមិនស្គាល់ឈ្មោះទេ ហើយក៏នៅមានខ្មាំងវាច្រើនទៀត ដែលយើងកំពុងតែស្រាវជ្រាវរកជាបន្តបន្ទាប់ នេះនៅក្នុងស្រុកមង្គលបូរី ។ នៅស្រុកបវិល កាលពីថ្ងៃទី៤-៥-៧៧ យើងចាប់វាបាន២ ក្បាល សួរចំលើយវា វាឆ្លើយថាមានលាក់កាំភ្លើងអាកា ១ ដើម កប់នៅទីក្រុងបាត់ដំបង ក្រោយមកយើងបាននាំវាទៅគាស់យកកាំភ្លើងនោះមកហើយ ចំណែកខ្មាំងនោះយើងបានកំទេចចោលហើយ ។ នៅតំបន់ទី៣ ដដែល ក៏មានចេញជាបាតុភាពខ្លះ ដូចជាខ្ជិលធ្វើការ ដៀលវាងមិនធ្វើពលកម្ម ពុតធ្វើជាឈឺ ធ្វើជាគមិនចេះនិយាយ ធ្វើជាឆ្កួត និងទាស់ទែងប្ដីប្រពន្ធ ខូចសីលធម៌ បុរសនារី ដែលមានប្ដីប្រពន្ធហើយ ។ ម្យ៉ាងទៀតក៏នៅមាន[illegible] កម្មសិទ្ធិឯកជននៅឡើយ គឺនៅមានលាក់លៀមរបស់របរប្រើប្រាស់ផ្សេងៗ មិនចង់ដាក់រួមនៅឡើយ ។ នៅតំបន់ទី៣ ដដែល ខ្មាំងធ្វើសកម្មភាពខ្លះៗទៀត ដូចជា វាធ្វើសកម្មភាពចាត់តាំងគ្នា វាឱ្យធ្វើកម្មភាពប្រមូលគ្នា វា និងកម្មភាពត្រៀមស្បៀងរត់ទៅសៀម មុននឹងវាចេញទៅ ពួកវាត្រៀមចាត់តាំងកម្លាំងស្រួចរបស់វា និងកំទេចបក្ស សហករណ៍ និងឈ្លបសហករណ៍ យកកាំភ្លើងការពារគ្នាវារត់ទៅសៀមតែម្ដង ។ សកម្មភាពនេះយើងបានពិនិត្យកន្លងមក សភាពជាក់ស្ដែងវាលេចចេញមកពីសមាសភាពទាហាន ពោលីសចាស់ និងពួកដែលមានបណ្ដាសក្ដិ ដូចជាសក្ដិ១ សក្ដិ២ សក្ដិ៣ រហូតដល់សក្ដិ៤ ដែលកប់នៅតាមសហករណ៍ កន្លងមកស្រាវជ្រាវមិនឃើញ ដល់ឥឡូវនេះឃើញលេចចេញជាសកម្មភាព ។ យើងមានវិធានការចាប់បានអស់ហើយ ។

តំបន់ទី៧ ជាសភាពការណ៍ខ្មាំង វាធ្វើចលនាទំនាស់មិនធ្វើពលកម្ម ទំនាស់សមូហភាព មានលាក់អង្ករបាយក្រៀម និងពុតជាឈឺមិនធ្វើពលកម្ម បំផុសសីលធម៌ និងលួចលាក់សំភារៈផ្សេងៗពីគ្នា ប្រឆាំងផែនការ ឱ្យយើងសំរេចផែនការមិនបាន ។

សភាពការណ៍មួយទៀត មានឈ្មោះអាវែតវាបំផុសចលនាថា មានទ័ពខ្មែរសេរីនៅបូព៌ា ១០០ តម្ព ស៊ីហនុជាអ្នកដឹកនាំ ហើយវាចលនាឱ្យរត់ទៅ ថាបានបុសវិទ្យុឈ្មោះមាតុភូមិ ។ ថាហ៊ីមទៅទាក់ទងស៊ីហនុនៅស្រុកបារាំង ត្រូវពួកនិយាយតែស្រុកបារាំងវាឈ្លាប់ហើយ ។ ថាខ្មៀវសំផន ទៅធ្វើការនៅខេត្តកំពត ពួកវាវាឈ្លាប់ដែរ ប្រវត្តិរបស់វាជាចៅសង្កាត់ សង្គ្រាមនេះពាក់សក្ដិ ៣ ។ បានមានវិធានការយកទៅហើយ ។ នៅសហករណ៍មេទឹក ។

ម្យ៉ាងទៀតឈ្មោះអែល ១ ភ្លួមួយ ផន១ វាចលនាថា មានទាហានមកពីលេចដល់បាត់ដំបង គឺជាទាហានលន់ណុល ហើយថានៅបាត់ដំបងគេហូបបាយឯកជន មានស្រូវពេញពុជក្រុក ។ ថានៅពោធិ៍សាត់ មានយោធារត់ចូលព្រៃច្រើន ។ ថាទាហានមកពីលេចរបស់លន់ណុល ចន្ទវង្ស មកពីកើតទាហានស៊ីហនុ ហើយបំផុសកុមារមិនប្រៀងចំរៀងបដិវត្ត មានវិធានការណ៍យោធាក្ដាប់ផ្ទាល់ហើយ ។

សរុប :

សភាពការណ៍ខ្មាំងទាំងខាងក្នុងទាំងខាងក្រៅឃើញថា វាធ្វើសកម្មភាពជាបន្តបន្ទាប់ តែសកម្មភាពទាំងអស់នេះ មិនខ្លាំងក្លាទេ វាមានវបេះវប៉ស់ ត្រង់នេះបន្តិចត្រង់នោះបន្តិច ។ តែខ្មាំងដែលចេញមុខមកទាំងប៉ុន្មាន ត្រូវយើងកំទេចបានជាបន្តបន្ទាប់ ។ ហើយយើងនៅមានវិធានការពារជាន់ និងបោសសំអាតវាតទៅទៀតជាប់ជានិច្ច ។

II សភាពការណ៍ប្រជាជន

យើងបានពង្រឹងរបបសមូហភាពនិយមរឹងប៉ឹងជាងមុនបានមួយកំរិត ។ ការរស់នៅរបស់ប្រជាជនក៏ឃើញថា មានការខ្វះខាតជាច្រើនតំបន់ ដូចជានៅតំបន់ទី១ តំបន់ទី២ តំបន់ទី៤ តំបន់ទី៦ និងតំបន់ទី៧ ដែលមានការខ្វះខាតច្រើនជាងគេសព្វថ្ងៃនេះ ។ នៅសមរភូមិក្រោយហូបបបរភាគច្រើន ឯនៅសមរភូមិមុខ តំបន់ខ្លះហូបបាយពីរកំប៉ុងមួយថ្ងៃ តំបន់ខ្លះទៀតហូបបបរមួយពេល ហូបបាយមួយពេល ។

ឯសំលៀកបំពាក់ប្រជាជនក៏មានការខ្វះខាតច្រើនដែរ តែកំពុងចាត់ចែងក្រណាត់ តាមការណែនាំរបស់អង្គការហើយ ។

អំបិលដែលអង្គការចែកជូនឃើញថា គ្រប់គ្រាន់គ្រប់កន្លែង ។ ឯជំរកប្រជាជនវិញ យើងបានចាត់ចែងធ្វើមួយចំនួនសំខាន់ហើយ ។ សព្វថ្ងៃនេះមិនមានប្រជាជនណាម្នាក់អត់ជំរកនៅ ដេកផ្ទាល់នឹងដី ដូចឆ្នាំ ១៩៧៥ ១៩៧៦ ទៀយ ។

សុខភាពប្រជាជនយើងក៏បានចាត់ចែង ចាក់ថ្នាំនិងបាញ់ថ្នាំ ការពារជំងឺគ្រុនចាញ់ទូទាំងភូមិភាគ សព្វថ្ងៃនេះជំងឺគ្រុនចាញ់ ឃើញថាធូរស្រាលជាងមុនឆ្ងាយណាស់ ។ តែក៏នៅមានប្រជាជនឈឺថ្កាត់ខ្លះដែរ នៅគ្រប់តំបន់ ជំងឺភាគច្រើនជាងគេគឺ រោគខ្សោយបាប់ រាកមួលនិងគ្រុនក្តៅ ។

III ការកសាងសង្គមនិយម

តំបន់ទី១ -
- ស្រែប្រាំងស្ទូងហើយបាន ៨៥ ហិកតា
- ដាំស្រូវស្រាលបាន ២៣ ហិកតា
- សាបស្រូវស្រាលបាន ៦០ បាវ
- ពោតដាំបាន ៤៩០ ហិកតា
- សណ្តែកដាំបាន ២៧៣ ហិកតា
- អំពៅដាំបាន ៣៥ ហិកតា
- ក្រចៅដាំបាន ២៥ ហិកតា
- ដំឡូងដាំបាន ៥០ ហិកតា
- បន្លែបង្ការផ្សេងៗដាំបាន ៣៨ ហិកតា
- ការចិញ្ចឹមសត្វ ឃើញថាបានចំរើនជាងមុន ដោយមានស្មារតីទទួលខុសត្រូវថែទាំ ធ្វើជំរកឱ្យវាបានមួយចំនួនហើយ យើងកំពុងដំណើរការជាបន្តបន្ទាប់ទៀត ។

ទំនប់ទឹកកក្កុត យើងបានចាក់ទ្វារទៀងហើយ តែមិនទាន់រួចរាល់នៅឡើយ កំពុងដំណើរការតទៅទៀត ។ ឯទំនប់ពីថ្ងៃទី២០-៥-៧៧ មានប្រេះធ្លាយទឹកបន្តិចត្រង់កណ្តាលទំនប់ តែយើងខ្ទប់ទៅវិញបាន សភាពការណ៍ទឹកឃើញថាច្រើនណាស់ ហើយវាសំរុកខ្លាំងផង ទឹកតាមទ្វារមិនទាន់ឱ្យហូរបានទេ តែសព្វថ្ងៃនេះ ទឹកហូរចេញតាមប្រឡាយទៅដល់ភ្ជួរបតីហើយ ។ ការសំរាកឃើញថា ទឹកវាធ្លាក់ខ្លាំង តែវាបញ្ហាញលឹត

តំបន់ទី២ :
- ស្រែប្រាំងបានស្ទូងហើយ ៩០០ ហិកតា
- សណ្តែកនិងពោតដាំបាន ១២៥៤ ហិកតា
- ទំនប់ធំៗមាន ៦ នៅមោង បាកាន និងក្រគរ
- អាងទឹកធំ ១ នៅបាណាក់ ។

តំបន់ទី៣ :
- ផ្ទះតំរូវ ៩៤ ខ្នង . ផ្ទះមតៀមមាន ៣០៧៨ ខ្នង
- អាងទឹកមតៀមមាន ១២ អាង
- ស្រែពកជីកមាន ២ ដែរ និងប្រឡាយធំៗមាន ៦ ប្រឡាយ
- ទំនប់មាន ១១
- ស្រះមាន ៣០
- មន្ទីរពេទ្យ ៣២ ខ្នង
- ស្រែធ្វើ២ដងសាបបាន ១៣២ ហិកតា
-

- ល្ហុងបាន ២៨៣០០ ហិកតា
- ដំឡូងឈើមួងស្លាបបាន១៧៥ ហិកតា ៤០ អា
- ព្រួលបាន ១៦៤៥០០ ហិកតា ៩០ អា
- ស្រូវកណ្ដាលស្លាបបាន ១៦ ហិកតា
- ព្រួលបាន ១០ ហិកតា
- មាន់មាន ៣៥.៨២៩ ក្បាល
- ទាមាន ៣៤.៩១២ ក្បាល
- ជ្រូកមាន ៤.៣២០ ក្បាល
- ភ្លឺមធំពុរធ្វើបានចំនួន៧៤.៨៩៥ ម៉ែត្រ បាត ២ ម៉ែត្រ ទៅ ៣ ម៉ែត្រ កំពស់ ៨ តឹក ទៅ ១ ម៉ែត្រ ខ្នងស្មើ ពី ៦ តឹក ទៅ ៧ តឹក ។
- ប្រព័ន្ធភ្លឺតូចកាត់ជាក្រឡាឈើត្រង់ បានចំនួន ៣៩.៥៧៦ ម៉ែត្រ
- ប្រឡាយទឹកធ្វើបានប្រវែង ៥៥.១៥៤ ម៉ែត្រ
- ទីចំការកបង្កាលភ្ជួររាស់កាប់គាស់បាន ៨៥ ហិកតា
- ក្រចៅព្រួលបាន ៤៦ ហិកតា ៣០ អា
- គដាំអស់ពូជ ៣ បាវ
- ពោតដាំបាន ៤២៥ ហិកតា ២០ អា
- សណ្ដែកបាយព្រួលបាន ១០៦ ហិកតា ៩០ អា
- ដំឡូងមីដាំបាន ៤០ ហិកតា

តំបន់ទី៤ :

- ចេកដាំបាន ១៦ ហិកតា
- អំពៅដាំបាន ៨១ ហិកតា
- ដូងដាំបាន ២០០ ដើម
- ស្វាយដាំបាន ១០០ ដើម ខ្នុរដាំបាន ១៧៩ ដើម
- ត្រឡាច ល្ពៅ ត្រសក់ ដាំបាន ៣៦ ហិកតា
- រោងជាងដែកស្ទ័ដក ១៨ កន្លែង និងរោងជាងល្អផាល ៨ កន្លែង ទៀតផ្ទ ៤ទៀ មានរោងសិប្បកម្មផ្សេងៗ ១៨ ខ្ទង់ក្នុង ១ ខ្ទង់មាន ២០ គី គីបូរាណ ១០ ពាក់កណ្ដាលស្វាយប្រវត្ត ១០
- មានរោងសង្គមកិច្ច ផរ៉ុំថ្នាំបូរាណ ១១ កន្លែង
- ថ្នាំកសិកម្មបានរៀបចំគ្រប់សហករណ៍ កន្លែងសហករណ៍ខ្លះពុំបានរៀបចំទេ
- ការដោះស្រាយជីវភាពលព្ទទីថ្វូរបបហូប អ្នកនៅខាងក្រោយឱយហូបម្ចាក់ ១ ថ្ងៃ៣កំប៉ុង អ្នកទៅពលកម្មខាងមុខ ក្នុង១ ថ្ងៃ ៣ កំប៉ុង នេះក្នុងស្រុកបវិល ។

តំបន់ទី៤ :

- ស្រែប្រាំងស្ទូងហើយ ៨០ ហិកតា
- ដាំស្រូវស្រាលបាន ៩០០ ហិកតា
- សាបស្រូវស្រាលបាន ៣៧ ហិកតា
- ស្រូវស្រាលស្ទូងហើយ ៦៥ ហិកតា
- ព្រួលស្រូវស្រុកបាន ៣០១ ហិកតា
- សាបស្រូវស្រុកបាន ២៨ ហិកតា
- ព្រួលស្រូវវ៉ាបាន ៣៤៧៣ ហិកតា
- ពោតដាំបាន ៨០៩ ហិកតា
- អំពៅដាំបាន ១៦ ហិកតា
- សណ្ដែកដាំបាន ១៧៨ ហិកតា

- ក្រចៅដាំបាន ៤០០ ហិកតា
- ដំឡូងដាំបាន ៨ ហិកតា ២២០ រង
- ត្រីដាំបាន ១០.០០០ គុម្ព
- ចេកដាំបាន ១៤.៨៩៣ គុម្ព
- ផ្ទះសង់ថ្មីបាន ៥៧១ ខ្នង
- ផ្ទះជួសជុល ១១៥៥ ខ្នង
- ជីរធម្មជាតិបាន ៤៥៤៩ តោន
- អាងទឹកមធ្យមធ្វើរួចហើយមាន៥ ក្នុងអាងមួយៗទំហំ ២ គីឡូម៉ែត្រ ៤ ជ្រុង

តំបន់ទី៥ :
- ពោតដាំបានត្រូវខូចអស់ពីរលើកហើយដោយរាំងពេក សណ្តែកក៏ដូចពោតដែរ
- ក្រចៅដំឡូង បន្លែបង្ការផ្សេងៗ ក៏ដូចគ្នាដែរ
- ការចិញ្ចឹមសត្វ បានយកចិត្តទុកដាក់ នឹងកំពុងរៀបចំទ្រុង ក្រោលជាបណ្តើរៗហើយ ។
- អាងទឹកយុទ្ធសាស្ត្រនៅត្រពាំងថ្ម កំពុងបន្តសំណង់ទ្វារទឹកទាំង ៣ នឹងបញ្ចប់ខាងនៅខែ១៥
- ព្រែកជីកប្រវែង ២៣ គីឡូម៉ែត្រ មាត់លើ ១២ ម៉ែត្រ បាតក្រោម ២ ម៉ែត្រ ជំរៅ ១ ម៉ែត្រ បានបញ្ចប់ហើយ ។ នៅស្រុកស៊ីសុផុន មានធ្វើប្រឡាយ ៤ នៅទំនប់កន្ទ្រងប្រវែង២២គ.ម នៅទំនប់សំរោង ប្រវែង ២ គីឡូម៉ែត្រ នៅទំនប់បន្លិច ប្រវែង ១ គីឡូម៉ែត្រកន្លះ នឹងនៅកន្លែង ១ទៀត ប្រវែង ២ គីឡូម៉ែត្រកន្លះ ។ នៅក្នុងសង្កាត់ប្រសាត កំពុងសំរុកព្រែកជីក១ ប្រវែង ៥០០ម មាត់លើ ១២ ម៉ែត្រ បាតក្រោម ៦ ម៉ែត្រ ជំរៅ ៤ ម៉ែត្រ ដែលជីកចេញពីស្ទឹងស្រែងមកអាងកៀរ មាត់បារ ។

តំបន់ទី៧ :
- ស្រូវប្រាំងស្ទូងហើយបាន ៣០០ ហិកតា
- សាបស្រូវស្រាលបាន ១០២២ បាវ
- សាបស្រូវកណ្តាលបាន ១១៦ បាវ
- សាបស្រូវធ្ងន់ ៥៨២ បាវ
- ស្ទូងស្រូវកណ្តាលបាន ១២៦ ហិកតា
- ស្រូវប្រាំងច្រូតបាន ១១ ហិកតា ១១៧០ ថាំង
- ផ្ទះសង់ថ្មីបាន ៣៧៤៨ ខ្នង
- អាងធំៗមាន ២ កន្លែងគឺ: ស្វាយដូនកែវ ១ នឹងបឹងកក់ ១ ។ ព្រមទាំងស្តារព្រែកជីកឲ្យជ្រៅថែមទៀត ។
- ការចិញ្ចឹមសត្វបានធ្វើក្រោលតូចៗ បានជាច្រើនកន្លែង ។ មានបានធ្វើទ្រុងឲ្យផុតពីដី ដើម្បីស្រួលងាយក្នុងការបោះសំអាត ។
- ពោតដាំបាន ៤៨ ហិកតា កន្លះ
- ក្រចៅដាំបាន ៣៨ ហិកតា
- ដំឡូងដាំបាន ៨៧ ហិកតា
- អំពៅដាំបាន ៥ ហិកតា
- ដំណាំបន្លែរបង្ការផ្សេងៗ ១៣៨ ហិកតា
- ពង្រីកភ្លឺចាស់បាន ៥៩ ហិកតា លើកភ្លឺថ្មីបាន ៣២៥ ហិកតា កន្លះ
- ជីរលេខ១ធ្វើបាន ២៨២៧ តោន លេខ២បាន ៧០៤ តោន លេខ៣បាន ១៦៦ តោន

ថ្ងៃទី ២៩- ខែ០៥- ឆ្នាំ ១៩៧៧

ម. ៥៦០